**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៧១
ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧

**សាលដីកា**
លេខ ៣១៨
ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០១៨

បានទទួល
01/08/2018 ម៉ោង 10:08 នាទីព្រឹក
Rub.
ជំនួយការមេធាវី
[redacted]

# សាលដីកា

តាងនាមប្រជាពលរដ្ឋខ្មែរ
តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ ៖

-លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ជាចៅក្រម
-លោក [redacted] ជាចៅក្រម
-លោក [redacted] ជាចៅក្រម
-លោកស្រី [redacted] ជាចៅក្រមរបាយការណ៍
-លោក [redacted] ជាក្រឡាបញ្ជី

**តំណាងមហាអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ១១៨ "ក្រVបស" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ។

១-ជនជាប់ចោទឈ្មោះ អ៊ិនវ៉ូកូ ព្រីហ្វ៊ីស ឈីនីមេ (Nwoko [redacted]) (អ្នកប្តឹងសាទុក្ខ) ភេទប្រុស អាយុ៦៣ឆ្នាំ ជនជាតិនីហ្សេរីយ៉ា កើតនៅប្រទេសនីហ្សេរីយ៉ា ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះជួលលេខ ១៧B ផ្លូវ ៥១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ Samuel Uche Mex "រ" ម្តាយឈ្មោះ Opolonia Nwoko "រ" (នៅលីវ)។ ឃុំខ្លួនថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ (នៅពន្ធនាគារម១) ។

- មានលោក [redacted] មេធាវីការពារសិទ្ធិ ។
- មានលោក [redacted] អ្នកបកប្រែភាសាអង់គ្លេស ។

២-ជនជាប់ចោទឈ្មោះ ថេល័រ យូសេ អាន ([redacted] Ann) (អ្នកប្តឹងសាទុក្ខ) ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិអូស្ត្រាលី មុខរបរគ្រូបង្រៀន កើតនៅប្រទេសអូស្ត្រាលី ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះលេខ ៣៣ ផ្លូវ Buckingham ក្រុង Mt Hallen Queensland Austalia ឪពុកឈ្មោះ Barry Taylor "រ" ម្តាយឈ្មោះ Marlene Wilson "រ" ប្តីឈ្មោះ Harley Young (លែងលះ) ។ ឃុំខ្លួនថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ (នៅពន្ធនាគារម២) ។

- មានលោក [redacted] មេធាវីការពារសិទ្ធិ ។
- មានលោក [redacted] អ្នកបកប្រែភាសាអង់គ្លេស

៣-ជនជាប់ចោទឈ្មោះ សាវ៉ារីណូ ហ្សាលីន (Savarino [redacted]) ភេទស្រី អាយុ១៩ឆ្នាំ ជនជាតិបារាំង មុខរបរធ្វើការនៅភោជនីយដ្ឋាន LaDuo កើតនៅប្រទេសបារាំង ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះលេខ ១៤ ផ្លូវ ៤៩ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ (នៅលីវ) ឪពុកឈ្មោះ Luigi Savarino "ស" ម្តាយឈ្មោះ Sylvie Rousselle "រ" ។ ឃុំខ្លួនថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ (នៅពន្ធនាគារម២) ។

៤-ជនជាប់ចោទឈ្មោះ Ojukwu [redacted] ហៅ NTO ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិនីហ្សេរីយ៉ា (Nigerian) កើតនៅ Onitsha ប្រទេសនីហ្សេរីយ៉ា ទីលំនៅផ្ទះលេខ ១A ផ្លូវលេខ ៤៥BT ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាន់លិខិតឆ្លងដែនលេខ A04657209 ។ (គេចខ្លួន)

៥-ជនជាប់ចោទឈ្មោះ Asemota [redacted] ភេទប្រុស ជនជាតិនីហ្សេរីយ៉ា កើតនៅក្រុងបេនីន ប្រទេសនីហ្សេរីយ៉ា (Benin city, Nigeria) កាន់លិខិតឆ្លងដែនលេខ A01170452 ។ (គេចខ្លួន)

<u>-ជាប់ចោទពីបទ</u> ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោស តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-តាមពាក្យបណ្តឹងសាទុក្ខលេខ ៤៥៩ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ Nwoko [redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១១៨ "ក្រV បស" ចុះថ្ងៃទី០៦ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច

-តាមបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ Taylor [redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១១៨ "ក្រVបស" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

**អំពីអង្គហេតុ**

-នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ សមត្ថកិច្ចប្រទេសអូស្ត្រាលីបានធ្វើការចាប់ខ្លួនជនជាតិអូស្ត្រាលីឈ្មោះ Cathryn [redacted] ភេទប្រុស អាយុ៤៤ឆ្នាំ និងឈ្មោះ David [redacted] Douglas ភេទប្រុស អាយុ៤២ឆ្នាំ នៅប្រទេសអូស្ត្រាលី ដកហូតបានម្សៅហេរ៉ូអ៊ីនចំនួន ០៨ គីឡូក្រាម ដែលជនល្មើសទាំងពីរបានទទួលពីជនត្រូវចោទឈ្មោះ Nwoko [redacted] ពីប្រទេសកម្ពុជា។ បន្ទាប់មកសមត្ថកិច្ចប្រទេសអូស្ត្រាលីបានផ្តល់ព័ត៌មានមកនាយកដ្ឋានភេរវកម្ម ក្រសួងមហាផ្ទៃ ។ នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ ឈ្មោះ Ojukwu [redacted] ហៅ NTO បានយកកាបូបស្ពាយមួយឱ្យជនត្រូវចោទឈ្មោះ Nwoko [redacted] នៅផ្ទះជួល១៧B ផ្លូវ ៥១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ដើម្បីប្រគល់ឱ្យឈ្មោះ Jonh ភេទប្រុស សញ្ជាតិអូស្ត្រាលីនៅ Brishane ប្រទេសអូស្ត្រាលី ។ នៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៣ វេលាម៉ោង ១១ និង ៣០ នាទីព្រឹក ឈ្មោះ Nwoko [redacted] បានប្រគល់កាបូបស្ពាយខាងលើទៅឱ្យឈ្មោះ Savarino [redacted] ប្រគល់បន្តឱ្យទៅជនត្រូវចោទឈ្មោះ Taylor [redacted] យកទៅប្រទេសអូស្ត្រាលីតាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ពេលដែលជនត្រូវចោទឈ្មោះ Savarino [redacted] និង Taylor [redacted] យកកាបូបចូល

ទៅក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក៏ត្រូវសមត្ថកិច្ចធ្វើការចាប់ខ្លួនអ្នកទាំងពីរព្រមទាំងឆែកឆេរកាបូបស្ពាយខាងលើរកឃើញម្សៅហេរ៉ូអ៊ីនទម្ងន់ ២០០២,៤០ ក្រាម និងបន្តចាប់ខ្លួនឈ្មោះ Nwoko [redacted] លុះក្រោយពេលចៅក្រមស៊ើបសួររួចមករក ឃើញឈ្មោះ Asemoto [redacted] ហៅ Justrice Edo ភេទប្រុស ជនជាតិនីហ្សេរីយ៉ា មានជាប់ពាក់ព័ន្ធក្នុងការទទួលគ្រឿងញៀននិងផ្ញើលុយឱ្យឈ្មោះ Nwoko [redacted] ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ <u>៥០</u>កប២ "៨" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោស៖

ក.ឈ្មោះ Nwoko [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិនីហ្សេរីយ៉ា (Nigerian) ដាក់ពន្ធនាគារកំណត់ចំនួន ២៧ (ម្ភៃប្រាំពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ។

ខ.ឈ្មោះ Savarino [redacted] ភេទស្រី អាយុ១៩ឆ្នាំ ជនជាតិបារាំង ដាក់ពន្ធនាគារកំណត់ចំនួន ២៥ (ម្ភៃប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល ។

គ.ឈ្មោះ Taylor [redacted] ភេទស្រី អាយុ២១ឆ្នាំ ជាតិអូស្ត្រាលី ដាក់ពន្ធនាគារកំណត់ចំនួន ២៣ (ម្ភៃបី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ឃ.ឈ្មោះ Ojukwu [redacted] ហៅNTO ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិនីហ្សេរីយ៉ា ដាក់ពន្ធនាគារកំណត់ចំនួន ២៧ (ម្ភៃប្រាំពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ។

ង.ឈ្មោះ Asemota [redacted] ភេទប្រុស ជាតិនីហ្សេរីយ៉ា ដាក់ពន្ធនាគារកំណត់ចំនួន ២៧ (ម្ភៃប្រាំពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ។

<u>ពីបទ</u> ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ Ojukwu [redacted] ហៅ NTO និងឈ្មោះ Asemota [redacted] យកមកទទួលទោសតាមអំណាចសាលក្រមនេះ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣.វត្ថុតាងដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ៥៩២វ.ត ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ របស់ឃ្លាំងតម្កល់វត្ថុតាងរបស់សាលាដំបូងរាជធានីភ្នំពេញ រួមមាន៖

ក.ហឹបដែកពណ៌សបិទជិត មានហត្ថលេខាគណៈកម្មការចូលរួមធ្វើការវេចខ្ចប់វត្ថុតាងនិងស្នាមមេដៃរបស់ជនសង្ស័យ ។តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៧៦៩ អ.យ.ង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ថា ម្សៅហេរ៉ូអ៊ីនទម្ងន់ ២០០២,៤០ (ពីរពាន់ពីរក្បៀសសែសិប) ក្រាម ។

ខ.ក្រដាសពណ៌ក្រហមវេចខ្ចប់គ្រឿងញៀន និងកាបូបស្ពាយពណ៌ខ្មៅមួយ ។

ត្រូវរឹបអូស ។

គ.ទូរស័ព្ទដៃម៉ាក HTC ពណ៌ខ្មៅមួយគ្រឿង ទូរស័ព្ទដៃម៉ាក HUAWEI ពណ៌សមួយគ្រឿង, ទូរស័ព្ទដៃម៉ាក សាំសុង GALAXYពណ៌សមួយគ្រឿង និងទូរស័ព្ទដៃម៉ាក សាំសុងស៊េរីចាស់គ្មានថ្មចំនួនមួយគ្រឿង ។

ឃ.លិខិតឆ្លងដែនរបស់ឈ្មោះ Nwoko [redacted] លេខ A01722130 ។

ង.លិខិតឆ្លងដែនរបស់ឈ្មោះ Nwoko [redacted] លេខ A01047063 ។

ច.លិខិតឆ្លងដែនរបស់ឈ្មោះ Taylor [redacted] លេខ A4277246 ។

ឆ.ម៉ូតូម៉ាក AIR BLADE ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AB5138 មួយគ្រឿង ។

ជ.រថយន្តម៉ាក CILECA ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2C 3335ចំនួនមួយគ្រឿង ។

ឈ.កុំព្យូទ័រយួរដៃម៉ាក ASUS ពណ៌ខ្មៅមួយគ្រឿង ។

ញ.កាបូបដៃចាស់ៗ ០២ ។

ដ.លោហធាតុពណ៌សមួយចំនួន (ខ្សែក ក្រវិល...) ។

ឋ.ឯកសារមួយចំនួន ។

ឌ.ឧបករណ៍អេឡិចត្រូនិចពណ៌ខ្មៅ ចំនួន ០២គ្រឿង ។

ឍ.កុំព្យូទ័រយួរដៃម៉ាក La Vie ពណ៌សមួយគ្រឿង ។

ណ.ឧបករណ៍សម្រាប់សាកថ្ម មួយចំនួន ។

ត.ឧបករណ៍ម៉ាក Hard Drive by HITACHI ចំនួន ០១គ្រឿង ។

ថ.នាឡិកាដៃចំនួន ០៦គ្រឿង ។

ទ.ប្រាក់ដុល្លារអាមេរិកចំនួន ៤៦១ដុល្លារ (បួនរយហុកសិបមួយ) ដុល្លារអាមេរិក ។

ធ.កាបូបស្ពាយសម្រាប់ដាក់កុំព្យូទ័រយួរដៃ ០១ ។

ន.វ៉ាលីដាក់ខោអាវ ០២ ។

ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ Nwoko [redacted] Chineme, ជនជាប់ចោទឈ្មោះ Taylor [redacted], ជនជាប់ចោទឈ្មោះ Savarino [redacted] កំបាំងមុខជនជាប់ចោទឈ្មោះ Ojukwu [redacted] ហៅ NTO និងជនជាប់ចោទឈ្មោះ Asemota [redacted] បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ខ.ក្រដាសពណ៌ក្រហមវេចខ្ចប់គ្រឿងញៀន និងកាបូបស្ពាយពណ៌ខ្មៅមួយ ។

ត្រូវរឹបអូស ។

គ.ទូរស័ព្ទដៃម៉ាក HTC ពណ៌ខ្មៅមួយគ្រឿង ទូរស័ព្ទដៃម៉ាក HUAWEI ពណ៌សមួយគ្រឿង, ទូរស័ព្ទដៃម៉ាក សាំសុង GALAXY ពណ៌សមួយគ្រឿង និងទូរស័ព្ទដៃម៉ាក សាំសុងសេរីចាស់គ្មានថ្មចំនួនមួយគ្រឿង ។

ឃ.លិខិតឆ្លងដែនរបស់ឈ្មោះ Nwoko [redacted] លេខ A01722130 ។

ង.លិខិតឆ្លងដែនរបស់ឈ្មោះ Nwoko [redacted] លេខ A01047063 ។

ច.លិខិតឆ្លងដែនរបស់ឈ្មោះ Taylor [redacted] លេខ A4277246 ។

ឆ.ម៉ូតូម៉ាក AIR BLADE ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AB5138 មួយគ្រឿង ។

ជ.រថយន្តម៉ាក CILECA ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2C 3335 ចំនួនមួយគ្រឿង ។

ឈ.កុំព្យូទ័រយួរដៃម៉ាក ASUS ពណ៌ខ្មៅមួយគ្រឿង ។

ញ.កាបូបដៃចាស់ៗ ០២ ។

ដ.លោហធាតុពណ៌សមួយចំនួន (ខ្សែក ក្រវិល...) ។

ឋ.ឯកសារមួយចំនួន ។

ឌ.ឧបករណ៍អេឡិចត្រូនិចពណ៌ខ្មៅ ចំនួន ០២គ្រឿង ។

ឍ.កុំព្យូទ័រយួរដៃម៉ាក La Vie ពណ៌សមួយគ្រឿង ។

ណ.ឧបករណ៍សម្រាប់សាកថ្ម មួយចំនួន ។

ត.ឧបករណ៍ម៉ាក Hard Drive by HITACHI ចំនួន ០១គ្រឿង ។

ថ.នាឡិកាដៃចំនួន ០៦គ្រឿង ។

ទ.ប្រាក់ដុល្លារអាមេរិកចំនួន ៤៦១ដុល្លារ (បួនរយហុកសិបមួយ) ដុល្លារអាមេរិក ។

ធ.កាបូបស្ពាយសម្រាប់ដាក់កុំព្យូទ័រយួរដៃ ០១ ។

ន.វ៉ាលីដាក់ខោអាវ ០២ ។

ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ Nwoko [redacted] Chineme, ជនជាប់ចោទឈ្មោះ Taylor [redacted], ជនជាប់ចោទឈ្មោះ Savarino [redacted] កំបាំងមុខជនជាប់ចោទឈ្មោះ Ojukwu [redacted] ហៅ NTO និងជនជាប់ចោទឈ្មោះ Asemota [redacted] បើកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៣៤ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ Precious [redacted] ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥០កប២ "ធ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច១ នៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៦១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ Yoshe [redacted] ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥០កប២ "ធ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៦៣ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ ហុង គឹមសួន មេធាវីការពារក្តី និងតំណាងដោយអាណត្តិឱ្យឈ្មោះ Charlene [redacted] ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥០កប២ "ធ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច១"២" នៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១១៨ "ក្រVបស" ចុះថ្ងៃ ទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៣៤ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ Nwoko [redacted], បណ្តឹងឧទ្ធរណ៍លេខ ៣៦១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ Taylor [redacted] និងបណ្តឹងឧទ្ធរណ៍លេខ ៣៦៣ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ Savarino [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥០កប២ "ធ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣.បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ Nwoko [redacted] ឈ្មោះ Taylor [redacted] និងជនជាប់ចោទឈ្មោះ Savarino Charlene និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ Nwoko [redacted], ឈ្មោះ Taylor [redacted] ឈ្មោះ Savarino [redacted] ។ បើកសិទ្ធិប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ ៤៥៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ឈ្មោះ Nwoko [redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១១៨ "ក្រVបស" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ Taylor [redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១១៨ "ក្រVបស" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញសារណាការពារ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ របស់ឈ្មោះ សូ មូស្សេទ្ធី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ Yoshe [redacted] ។

## នាពេលសវនាការ

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា សាលាដំបូងនិងសាលាឧទ្ធរណ៍ បានសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ Nwoko [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ ជនជាតិនីហ្សេរីយ៉ា ដាក់ពន្ធនាគារកំណត់ចំនួន ២៧ (ម្ភៃប្រាំពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល និងជនជាប់ចោទឈ្មោះ Yoshe [redacted] ភេទស្រី អាយុ៦១ឆ្នាំ ជនជាតិអូស្ត្រាលី ដាក់ពន្ធនាគារកំណត់ចំនួន ២៣(ម្ភៃបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន)រៀល មានលក្ខណៈត្រឹមត្រូវហើយ ។ ពីព្រោះថា សមត្ថកិច្ចបានឃាត់ខ្លួនជាក់ស្តែងជនជាប់ចោទឈ្មោះ Yoshe [redacted] ដែលមានវត្ថុតាងជា ថ្នាំញៀន ពីជនជាប់ចោទនៅ ព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដែកនៅក្នុងកាបូបស្ពាយរកឃើញម្សៅហេរ៉ូអ៊ីនទម្ងន់ ២០០៤,៤០ និងវត្ថុតាងផ្សេងៗទៀតដូចមាននៅក្នុងកំណត់ហេតុដក ហូតបន្ទាប់មកសមត្ថកិច្ចក៏ឈានទៅឃាត់ខ្លួនជនជាប់ចោទពីរនាក់ទៀតឈ្មោះ Nwoko [redacted] និងឈ្មោះ Savarino [redacted] ដែលជនជាប់ចោទទាំងពីរនាក់នេះ ពិតជាមានទំនាក់ទំនងនាំចេញគ្រឿងញៀនដោយខុសច្បាប់ តាមរយៈទទួលយកបន្តនូវកាបូបមានគ្រឿងញៀន ដែលលាក់ទុកក្នុងកាបូបធ្វើងកាត់ព្រលានយន្តហោះអន្តរជាតិភ្នំពេញទៅអូស្ត្រាលី ។ ម្យ៉ាងទៀតផ្អែកតាមការផ្តល់ពត៌មានរបស់ប្រទេសអូស្ត្រាលី ជនជាប់ចោទទាំងបីនាក់មានទំនាក់ទំនងនាំចេញថ្នាំញៀនពីប្រទេសកម្ពុជាទៅប្រទេសអូស្ត្រាលីពិតប្រាកដ ។ ថ្នាំញៀនដែលសមត្ថកិច្ចដកហូតបានតាមលទ្ធផលកោសល្យវិច័យបញ្ជាក់ជាវិជ្ជមាន វត្ថុមានសារធាតុញៀនឈ្មោះ ហេរ៉ូអ៊ីន គិតជាភាគរយនៃទម្ងន់គឺ ៦៣.៨៤% = ១២៧៧,៩៣ ក្រាម គឺត្រូវឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តាមរយៈការបញ្ជូន

ដែលនាំឱ្យមានការផ្លាស់ទី ពីកន្លែងមួយទៅកន្លែងមួយទៀត ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយ ទៅប្រទេសមួយ ដោយខុសច្បាប់ នូវសារធាតុញៀនជាអាទិ៍ តាមរយៈការធ្វើចរាចរ ការនាំចេញ គឺជាអំពើដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) រាល់ទង្វើរបស់ជនជាប់ចោទ ទាំងបីនាក់ពិតជាបានប្រព្រឹត្ត និងសារភាពថា ពួកខ្លួនជាអ្នកទទួលយកកាបូប និងពួកខ្លួនជាអ្នកយកកាបូបប្រគល់ឱ្យទៅបន្ត ដោយមានឈ្មោះ Nwoko [redacted] ឈ្មោះ Yoshe [redacted] និងឈ្មោះ Savarino [redacted] ដែលមានសារធាតុញៀននៅក្នុងកាបូបស្ពាយពណ៌ខ្មៅជាកម្មវត្ថុនៃការប្រព្រឹត្តបទល្មើស ។ ដូចនេះ រាល់សំអាងហេតុនៃសាលក្រម របស់សាលាដំបូង និងសំអាងហេតុរបស់ សាលាឧទ្ធរណ៍ បានបង្ហាញភស្តុតាងគ្រប់គ្រាន់ ដាក់បន្ទុកទៅលើជនជាប់ចោទទាំងបីនាក់ ត្រឹមត្រូវតាមច្បាប់ហើយ ។ ចំពោះជនជាប់ចោទឈ្មោះ Nwoko [redacted] ពុំបានដាក់សារណាតាមការបង្គាប់របស់តុលាការនោះឡើយ គប្បីក្រុមប្រឹក្សាពិចារណាតាមមាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ហេតុដូច្នេះ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច ទទួលបណ្តឹងសាទុក្ខលេខ ៤៥៤ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ឈ្មោះ Nwoko [redacted] និងបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ Yoshe [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែទាស់នឹងគតិច្បាប់ ។ តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១១៨ "ក្រVបស" ចុះថ្ងៃ ទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ។

## ដំណាក់កាលសួរដេញដោល

-ជនជាប់ចោទឈ្មោះ Nwoko [redacted] ( មានអ្នកបកប្រែលោក លឹម សុគន្ធ ) បានឆ្លើយថា ខ្លួនមិនសុខចិត្តនឹងការសម្រេច របស់សាលាឧទ្ធរណ៍ ដោយសារខ្លួនមកកម្ពុជាពិភាក្សារឿងរកស៊ីទេ ខ្លួនត្រូវការឃើញភស្តុតាងដែលគេបង្ហាញជូនតុលាការធ្វើឱ្យប៉ូលីសឃាត់ខ្លួន សំអាងថា អាជ្ញាធរកម្ពុជា គេឃាត់ខ្លួនរូបខ្លួននេះមានមូលហេតុអ្វី ព្រោះពេលប៉ូលីសមកឆែកឆេរផ្ទះខ្លួនមិនបានបង្ហាញដីកាទេប៉ូលីសកម្ពុជាមិនបានធ្វើតាមច្បាប់កម្ពុជាទេ ពេលប៉ូលីសមកឆែកឆេរផ្ទះខ្លួនបើកទ្វារហើយ ខ្លួនសួរថា មានរឿងអ្វី ប៉ូលីសមិនបានបង្ហាញលិខិតស្នាមទេ មាត្រាតាម ៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការឆែកឆេរត្រូវមានដីកា ឯមាត្រា ៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឃាត់ខ្លួនគ្មានអ្នកបកប្រែនិង គ្មានមេធាវី ឯមាត្រា៧១ តាមច្បាប់ប៉ូលីសត្រូវបង្ហាញដីកាឆែកឆេរនិងដីកាចាប់ខ្លួន តែប៉ូលីសមិនបានបង្ហាញភស្តុតាងអ្វីទេ ក៏ចាប់ខ្លួនតែម្តង ។ ហើយដីកាត្រូវចេញដោយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ។

-ច្បាប់កម្ពុជាតម្រូវបង្ហាញកស្តុតាង តែពេលឆែកឆេរផ្ទះ ប៉ូលីសមិនឱ្យខ្លួនទាក់ទងទៅខាងក្រៅទេ មាត្រា ៩៦ ប៉ូលីសបានធ្វើខុសនីតិវិធី មិនឱ្យខ្លួនទាក់ទងទៅខាងក្រៅរហូត ។ ការចាប់ខ្លួនមិនបង្ហាញដីកាចាប់ខ្លួន និងមិនឱ្យខ្លួនទាក់ទងទៅក្រៅគឺខុសច្បាប់ ។

ខ្លួនមកកម្ពុជាដើម្បីរកស៊ី និងធ្វើកម្មសិក្សាវិទ្យាពេទ្យនៅមន្ទីរពេទ្យរុស្ស៊ី កម្មសិក្សាពេទ្យហើយការមកនេះគឺធ្វើដោយស្របច្បាប់ មានការអនុញ្ញាតឱ្យធ្វើកម្មសិក្សាពីក្រសួងអប់រំប្រទេសខ្លួនឱ្យនៅកម្ពុជារយៈពេល ៤ឆ្នាំ ក្នុងរយៈពេលនេះ ខ្លួនបានរកស៊ីនាំទំនិញចេញពីកម្ពុជាទៅអូស្ត្រាលី ទំនិញដែលនាំចេញនោះមានដូចជា សម្លៀកបំពាក់ ស្បែកជើង ក្រណាត់ប៉ាក់ និងគ្រឿងអេឡិចត្រូនិចខ្លះ មានដូចជា នាឡិកា ទូរស័ព្ទ ពីអូស្ត្រាលីមកកម្ពុជាវិញជាដើម ។

អំពីទំនាក់ទំនងរវាងខ្លួននិងឈ្មោះ Savarino [redacted] បានស្គាល់រយៈពេល១ឆ្នាំ ៧ខែ ហើយក៏ស្គាល់គ្រួសាររបស់នាងច្បាស់ដែរ ។ ការផ្ញើទំនិញ និងទំនាក់ទំនងរកស៊ីជាមួយគ្នា នាងមិនដែលបានធ្វើដំណើរជាមួយខ្លួនទេ នាងធ្វើការនៅភោជនីយដ្ឋានស្គាល់តែឈ្មោះទេ។

ឈ្មោះ David [redacted] ខ្លួនមិនបានស្គាល់ថាជាអ្នកណាទេ ខ្លួនស្គាល់តែឈ្មោះ Ojukwu [redacted] ខ្លួនស្គាល់បានតែរយៈពេល ១សប្តាហ៍ជាងទេ ក៏ប៉ូលីសចាប់ខ្លួន ។ ខ្លួនមិនដឹង ហើយក៏មិនស្គាល់អ្នកណាទេ សំខាន់មានកស្តុតាងចោទលើខ្លួន កស្តុតាងនៅអូស្ត្រាលីមិនមានក្រយៅដៃរបស់ខ្លួនទេ ។

ទំនាក់ទំនងខ្លួននិងឈ្មោះ Yoshe [redacted]បានស្គាល់តាមរយៈអ៊ីនធើណេត មិនចាំថាស្គាល់គ្នាពេលណាទេ ការស្គាល់ឈ្មោះ Yoshe [redacted] ក្នុងបំណងរកស៊ីបើកហាង ពេលឈ្មោះ Yoshe [redacted] មកកម្ពុជាម្តងៗចំណាយក្នុងការស្នាក់នៅនិងការធ្វើដំណើរពីអូស្ត្រាលីជួនកាលគេចេញលុយខ្លួនឯង ជួនកាលខ្លួនជួយចេញឱ្យឈ្មោះ Yoshe [redacted] មកកម្ពុជាចុងក្រោយមិនបានជួប និងទំនាក់ទំនងគ្នាទេ សូម្បីទទួលនៅព្រលានយន្តហោះ ខ្លួនមិនបានទៅទទួលផង ។ Yoshe [redacted]មកផ្តើមរកស៊ីជាមួយខ្លួន ឯការដើរលេងស្និតស្នាលជាមួយតែឈ្មោះ Savarino [redacted] ទេ ។ នៅថ្ងៃអាជ្ញាធរចាប់បានគ្រឿងញៀន ការរៀបចំកាបូបឱ្យ Yoshe [redacted] គឺ Yoshe [redacted]និយាយខ្លួនឯងទេ ។

-ឯកាបូបគឺមនុស្សផ្សេងទេ ជាអ្នកទិញកាបូបនោះយកមកផ្ទះខ្លួនពេលយកចេញវិញគឺ Yoshe [redacted] ជាអ្នកយកចេញទៅវិញដែរ ។

-លុយមាននៅធនាគារ និងទិញឡាននៅកម្ពុជាគឺបានពីការរកស៊ីរបស់គ្រួសារខ្លួនទេ ការពិតមានលុយ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក នៅធនាគារអេស៊ីលីដា និងទិញឡានអស់

ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ។ ការផ្ញើរកាបូបយួរដៃចំនួន ៦លើក គឺផ្ញើររបស់ចម្លាក់ទៅអូស្ត្រាលី ។

-របស់ដែលខ្លួនផ្ញើគឺជាវត្ថុសិល្បៈមិនមែនជាគ្រឿងញៀនទេ ។ លើកទី៦បានរៀបចំកាបូប១ប្រើ Savarino [redacted] ផ្ញើរកាបូបនេះជាមួយឈ្មោះ ហាលេអិនទ្រូ ខ្លួនមិនស្គាល់ឈ្មោះ ហាលេអិនទ្រូ ទេ ។ ខ្លួនផ្ញើទៅជាវត្ថុសិល្បះទេ ឯអាជ្ញាធរអូស្ត្រាលីឆែកឃើញក្នុងកាបូបមានវត្ថុអនុស្សាវរីចម្លាក់មែន និងមានគ្រឿងញៀន ។ ខ្លួនទទួលស្គាល់ថាបានផ្ញើតែវត្ថុចម្លាក់ទេ ឯការផ្ញើកាបូបមិនដែលផ្ញើរដែរ ។

ឪពុកម្តាយខ្លួនមានមុខរបរជាអ្នកលក់ដូរ ។ វត្ថុតាងដែលអាជ្ញាធរអូស្ត្រាលី បង្ហាញនិងចាប់បាននៅឯណា? ខ្លួនមិនបាននិយាយអ្វីទម្លាក់កំហុសលើ ស្សាលែន Charleme មិត្តស្រីខ្លួនទេ ការរៀបចំកាបូបនាងរៀបចំខ្លួនឯង ។ ខ្លួនមកស្រុកខ្មែរបីដងប្រើ Passport ចំនួនពីរ ១ប្រើតាមជនជាតិឪពុក ១ប្រើតាមជនជាតិម្តាយ ។ កាបូប គឺ ស្សាលែន Charleme មកយកពីផ្ទះខ្លួនគឺមិនមែន កាបូបទេ ជាសំពាយសិស្ស មិនមែនពណ៌ខ្មៅទេ ឯថាមានគ្រឿងញៀនក្នុងនោះខ្លួនមិនដឹងទេ ឯឈ្មោះ Ojukwu [redacted] ហៅ NTO បានផ្ញើរកាបូបនៅផ្ទះខ្លួនមែន រយៈពេល ៤-៥ ថ្ងៃរក្សាទុកក្នុងផ្ទះខ្លួន ។ ពេលផ្ញើមិនបានឃើញមានអ្វីក្នុងកាបូបទេ ខ្លួនបានឆែកមើលជាមួយ Charleme វត្ថុផ្ញើទៅអូស្ត្រាលីខ្លួនដើរទិញពីផ្សារ ត្រង់យកដាក់មិនដាក់ខ្លួនមិនដឹងទេ កាបូបឈ្មោះ NTO ជាអ្នកទិញ ឯវត្ថុសិល្បៈដើរទិញជាមួយគ្នា ខ្លួនជាអ្នកចេញលុយ ហើយផ្ញើតាម Taylor ពេល Taylor កាន់កាបូបទៅក៏មិនដឹងថា Taylor បានទទួលលុយអ្វីដែរ ចំពោះលុយ ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ជាលុយខ្ចីទេ ពេលផ្ញើតាមកាបូបក៏មិនបានប្រាប់ថាឱ្យផ្ញើ ឬយកតាមខ្លួនទេ ។ ខ្លួនស្នាក់នៅកម្ពុជាមានគេស្គាល់ច្រើនណាស់ ខ្លួនមិនដែលធ្វើអ្វីខុសទេ ។

-ជនជាប់ចោទឈ្មោះ Yoshe [redacted] (មានអ្នកបកប្រែឈ្មោះ កក់ថន សុខខេង) បានឆ្លើយថា: សវតាជាតិខ្លួនក្នុងសំណុំរឿងត្រឹមត្រូវហើយ ខ្លួនមិនសុខចិត្តនឹងការសម្រេចរបស់សាលាឧទ្ធរណ៍ដោយហេតុថា: ថ្នាំញៀនគេរកឃើញក្នុងកាតាប ខ្លួនមិនដឹងថាជាថ្នាំញៀនទេ ។ ពាក់ព័ន្ធនឹងការស្គាល់ Nwoko [redacted] គឺនៅដើមឆ្នាំ២០១៣ ខ្លួនប្រើ Internet ដំបូងទូរស័ព្ទខ្លួនអាចប្រើ Internet តាមរយៈផ្កាយរណបបាន ហើយចាប់ផ្តើមទំនាក់ទំនងជាមួយមនុស្សតាមInternet មានវេបសាយ ក៏ចាប់ផ្តើមស្គាល់ Nwoko [redacted] តាមវេបសាយ គាត់ថាគាត់មានអាយុ៤៤ឆ្នាំ ហើយក៏ចាប់ផ្តើមនិយាយគ្នាពីរឿងការងារ ហើយក៏បាននិយាយពីរឿងស្នេហាដែរ តែខ្លួនមិនស៊ីជម្រៅទេ ដោយមិនទាន់ស្គាល់គ្នាច្បាស់ ។ ឈ្មោះ Nwoko [redacted] chineme ថាគាត់ជាអ្នករកស៊ីនាំចេញទំនិញពីកម្ពុជាមានតម្លៃថោក ហើយគាត់ចង់មានអ្នកនៅ

អូស្ត្រាលីទទួលយកទំនិញ ទៅលក់នៅកន្លែងផ្សេងៗ គាត់ត្រូវការមនុស្សជួយយកទៅលក់ ។ ខ្លួនមិនដែលទទួលលុយពីឈ្មោះ Nwoko [redacted] ទេ ។ កន្លងមកមានផ្ញើរបស់ពី២ ទៅ៣ដង ជារបស់របរគ្រឿងទូរស័ព្ទ ។ ដំបូង Nwoko [redacted] សួរខ្លួនថា មានចង់រកស៊ីនៅស្រុកខ្មែរទេ សួរពីរទៅបីដងខ្លួនក៏យល់ព្រមមកកម្ពុជា តែឈ្មោះ Nwoko [redacted] ចេញថ្លៃយន្តហោះឯការស្នាក់នៅហូបចុកចេញខ្លួនឯង ។ ពេលនៅកម្ពុជាគេនាំដើរលេងខេត្តកំពត ខ្លួននៅកម្ពុជាតែ ៥ថ្ងៃទេ នៅផ្ទះ ឯឈ្មោះ Nwoko [redacted] ចេញក្រៅផ្ទះបាត់ៗ ។

ក្នុងឆ្នាំ២០១៣ ប្រហែលក្នុងខែសីហា លោក ច័ន្ទ នៅកម្ពុជាជាអ្នកទទួលបន្ទុកផ្ញើគ្រឿងសិល្បៈខ្លួន មិនដែលជួបលោក ច័ន្ទ ទេ ។ លើកទី២ឈ្មោះ Nwoko [redacted] បានផ្ញើរបស់តាមខ្លួនមានកាបូបចំនួន ១ រាងដូចវ៉ាលី តែមានប្រដាប់យួរដៃវែង មិនបានមើលទេ Pricious បើកមើលខ្លួនឯងឃើញមានគ្រឿងចម្លាក់ឈើលាបពណ៌ទឹកមាសស្រដៀងថ្មាទីន មានចំនួន៤ ស្រដៀងគ្នា រូបចម្លាក់លើកដៃសំពះ រូបតូចៗល្មម មួយកាន់ដៃ ។ ៤ក្នុងកាបូប មួយកាន់ដៃសរុប ៥រូប ។ ខ្លួនមិនសង្ស័យថា ក្នុងកាបូបមានអ្វីទេ តែខ្លាចគេសង្ស័យថាខ្លួនលួចរបស់ទៅវិញទេ ។ ហើយគិតថា គេផ្ញើរបស់តាមរយៈខ្លួន ដើម្បីសន្សំសំចៃ ។

- ការចុះកិច្ចសន្យាជាមួយឈ្មោះ Nwoko [redacted] មាន៦ទំព័រមុននឹងចុះកិច្ចសន្យាខ្លួនបានអានជាច្រើនដង ក្នុងកិច្ចសន្យាខ្លួនបានទទួលប្រាក់សមល្មមអាចទទួលយកបាន ហើយមានសុវត្ថភាពក្នុងការផ្ញើរហិរញ្ញវត្ថុជាមួយការងារ ប្រាក់ខែគេសន្យាថា ឱ្យពី ១៥.០០០ ដុល្លារ ទៅ ១៦.០០០ ដុល្លារ ក្នុង១ខែ ។ ខ្លួនជឿជាក់លើ ដោយសារតែជាមិត្តភ័ក្តបានជជែកគ្នាជាញឹកញាប់ ហើយមានចិត្តល្អ ពេលជួបគ្នាប្រឹក្សាជាមួយ ស្តេម៉ា ឃើញថា Nwoko Precious [redacted] ទុកចិត្តបានទៅ ។

លើកទី២ ពេលទៅអូស្ត្រាលីដើម្បីរកកន្លែងលក់ដូរ ក្នុងអំឡុងលើកទី២ ពេលខ្លួនឈឺបានទៅពេទ្យ ។ ពេលរកទីតាំងលក់ឃើញថាតម្លៃលក់ថ្លៃជាងគេ ចង់បើកដោយរបស់ថ្លៃក៏មកជួបឈ្មោះ Nwoko [redacted] ដើម្បីពិភាក្សាបន្តលើកទី៣ ។

លើកទី៣ ប្រហែលជាក្នុងថ្ងៃទី២៦ ខែកញ្ញា នៅព្រលានយន្តហោះ ខ្លួនគិតថា Nwoko [redacted] ទៅទទួលខ្លួន តែតាមពិតឈ្មោះ Savarino Charlene ជាអ្នកទៅទទួលខ្លួន ។ ឈ្មោះ Savarino [redacted] ទើបស្គាល់ពេលជួបគ្នាទេ កាលពីមុនមកពុំដែលស្គាល់គ្នាទេ ។ ឈ្មោះ Savarino [redacted] បាននាំខ្លួនទៅសណ្ឋាគារ ២-៣ ម៉ោងក្រោយមកឈ្មោះ Nwoko Precious [redacted] បានទៅជួបខ្លួន ។ ពេលរសៀលឈ្មោះ Savarino [redacted] នាំខ្លួនទៅ

ទទួលទានអាហារ ភាគច្រើនចំណាយពេលក្នុងបន្ទប់ ពេលមួយគេនាំខ្លួនទៅចុះកិច្ចសន្យានៅ វីស៊ិតមួយ តែពុំស្គាល់ទីតាំងទេ ។ ពេលដំបូងឈ្មោះ Nwoko [redacted] ថាឱ្យខ្លួនចំនួន ២០.០០០ ដុល្លារ ដើម្បីបើកហាងនៅអូស្ត្រាលី តែបើកមិនបានព្រោះរបស់ថ្លៃ ។ តាមពិតមិនមែនជាកុងត្រាអ្វីទេ គ្រាន់តែជាក្រដាសមួយសន្លឹក ហើយថា ឱ្យខ្លួន ១០.០០០ ដុល្លារ ពេលខ្លួនត្រឡប់ទៅអូស្ត្រាលីវិញថ្ងៃចុងក្រោយពេលទៅអូស្ត្រាលីឈ្មោះSavarino [redacted]មកសណ្ឋាគារយកកាបូប១ផ្ញើខ្លួនទៅអូស្ត្រាលី ។

-ប្រាក់ចំនួន ២៥.០០០ ដុល្លារ សម្រាប់ជួលកន្លែង (ក្នុងលុយចំនួន ៥០.០០០ ដុល្លារ) ជាតួលេខទេ ការពិតជាក់ស្តែងគ្មានលុយទេ ថ្ងៃចុងក្រោយគេបាន ផ្ញើកាបូបមួយតាមខ្លួនហើយ បានបើកកាបូបឱ្យខ្លួនមើលក៏មិនឃើញអ្វីចម្លែកដែរ តែមិនអស់ចិត្តពេលទៅដល់បន្ទប់ខ្លួនក៏បាន បើកមើលម្តងទៀតហើយបានថតទុក ព្រោះខ្លាចគេចោទថា លួចរបស់ ពេលខ្លួនយួរកាបូបនោះ មានអារម្មណ៍ថា ដូចជាធ្ងន់ៗដែរតែ ខ្លួនក៏បានបើកមើលមិនឃើញអ្វីចម្លែកនិង ក៏គិតថាវីដោយសារតែខ្លួនឈឺ ទើបលើកទៅធ្ងន់ មិនចាប់អារម្មណ៍រហូតដល់វះកាបូបមើលទេ ។

មូលហេតុខ្លួនទុកចិត្តឈ្មោះ Savarino [redacted] ដែលទើបស្គាល់ព្រោះថា ការទទួលបញ្ញើនេះដោយសារគិតថាឈ្មោះ Savarino [redacted] សហការីម្យ៉ាងទៀតពិនិត្យតាមកិច្ចសន្យាមិនឃើញមានអ្វីខុសច្បាប់ប្រទេសកម្ពុជា និងខុសច្បាប់របស់ប្រទេសអូស្ត្រាលីទេ ពេលគេរកឃើញមានថ្នាំញៀនក្នុងកាបូបខ្លួននេះ ប៉ូលីសអូស្ត្រាលីបានប្រាប់ខ្លួនថាក្នុងកាបូបផ្ញើរលើកទី ២ ក៏មានគ្រឿងញៀនដែរ។

ពេលឈ្មោះ Savarino [redacted] យកកាបូបមកផ្ញើបានប្រាប់ថា កាបូបនេះឈ្មោះ Nwoko Precious [redacted] ជាអ្នកឱ្យយកមកផ្ញើ ។ ដំបូងមិនចង់ទទួលបញ្ញើរទេ ព្រោះខ្លួនឈឺតែគិតថា ក្នុងវ៉ាលីខ្លួនទំនេរហើយបើបាត់របស់ខ្លួននឹងសងគេ ក៏ទទួលរក្សាទុកទៅ ។ ឈ្មោះ Savarino [redacted] ថាអ្នកផ្ញើរគឺ ឈ្មោះ Nwoko [redacted] ផ្ញើ ។ ការពិតលុយ ១.០០០ ដុល្លារ គេឱ្យខ្លួនថ្លៃការងារមកកម្ពុជា ដើម្បីចំណាយលើការស្នាក់នៅ និងម្ហូបអាហារ លុយនេះគេឱ្យពេលចុះកិច្ចសន្យារួចហើយ ។ ឈ្មោះ Savarino [redacted] ថាបើផ្ញើបាត់ឱ្យខ្ញុំសង ។ ពេលធ្វើដំណើរចេញពីតាក់ស៊ីឈ្មោះ Nwoko [redacted] ហុចវ៉ាលីឱ្យខ្លួនកាន់វិញ ។លើកទី១ ឈ្មោះ Nwoko [redacted] ប្រាប់ថានឹងមានរបស់ផ្ញើតាមខ្លួន ។សូមទុកសិទ្ធិឱ្យមេធាវីធ្វើការសន្និដ្ឋានបន្ថែម ។

-មេធាវី អ៊ឹង ម៉េងហ៊ាង ការពារសិទ្ធិឱ្យឈ្មោះ Nwoko [redacted] បានសន្និដ្ឋានថា ឈ្មោះ Nwoko [redacted] បានលើកឡើងរួចហើយតាំងពីដំបូងមកថា អ្វីគាត់បាន

ធ្វើ តែរបស់របរទាំងអស់ក្នុងវ៉ាលីរបស់គាត់ ប៉ូលីសមិនបានកំណត់ថា វ៉ាលីរបស់ឈ្មោះ Nwoko Precious [redacted] មែន ឬមិនមែនព្រោះឈ្មោះ Nwoko [redacted] ផ្ញើមានតែរូបចម្លាក់ទេ កាបូបដែលតុលាការបង្ហាញមិនមែនជាកាបូបរបស់ឈ្មោះNwoko [redacted] ផ្ញើតាមរយៈឈ្មោះ Yoshe [redacted] ទេសាលាដំបូង និងសាលាឧទ្ធរណ៍មិនបានបង្ហាញថាកាបូបដែលផ្ញើជាកាបូបដែលអាជ្ញាធរចាប់បានឬទេ ?សូមពិចារណាច្បាប់ ។

-លោកមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ Yoshe [redacted] បានសន្និដ្ឋានថា ជាសេចក្តីសង្ខេប នៃសារណាការពារបណ្តឹងសាទុក្ខ និងពាក្យសុំទាំងឡាយបានដាក់ជូនតុលាការកំពូលរួចហើយសុំរក្សាខ្លឹមសារសារណាការពារនៅដដែល ចំពោះសាលដីកាសាលាឧទ្ធរណ៍ ក៏ដូចសាលក្រមសាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច ពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ទេ ។Yoshe [redacted] បានសាទុក្ខមកនេះ ដោយហេតុផលដូចខាងក្រោម :-

-យោងតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាមូលហេតុនៃបណ្តឹងសាទុក្ខគឺ

ទី១ . ការរំលោភអំណាច ទី២. ការគ្មាន សំអាងហេតុ ទី៣ .ការបំភ្លៃអង្គហេតុ ទី៤.ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់ ហេតុអ្វីឈានដល់ដំណាក់កាលនេះ ?

-ឈ្មោះ [redacted] នៅទីនេះ គាត់ជាប់ឃុំជិត៥ឆ្នាំហើយ តុលាការថ្នាក់ក្រោមផ្តន្ទាទោសYoshe [redacted] ពីបទ ល្មើសជំនួញជួរណាស់គាត់បានព្រាត់មនុស្សជាទីស្រលាញ់ និងមិនដែលបានជួបមុខកូនជាទីស្រលាញ់ និងពុំបាន ជជែកប្រាស្រ័យទាក់ទងជាមួយកូននិងគ្រួសាររបស់គាត់ទេ ។

ផ្អែកតាមភស្តុតាង Yoshe [redacted] ជាជនរងគ្រោះ គេមិនដាក់ទោសជនរងគ្រោះទេ មិនដាក់ជនរងគ្រោះក្នុងពន្ធនាគារដោយគ្មានកំហុសដែរគេក៏មិនបំបែកជនរងគ្រោះពីមនុស្សជាទីស្រលាញ់គួរតែផ្តល់ឪកាសឲ្យជនរងគ្រោះកសាងជីវិតថ្មីបានចូលរួមសង្គមនិងគួរតែការពារជនរងគ្រោះពីឧក្រិដ្ឋជនដែលបានកេងប្រវ័ញ្ចធ្វើឱ្យជនរងគ្រោះមានការឈឺចាប់។ រឿងនេះតុលាការបានផ្តន្ទាទោសលើ Yoshe [redacted] ផ្អែកលើភស្តុតាងប្រយោល ។ច្បាស់លាស់ការមានវិមតិសង្ស័យជាប្រយោជន៍ដល់ជនជាប់ចោទ និងការសន្មត់ទុកជាមុនថាគ្មានទោសទាំងអស់នេះជាសិទ្ធិធានាការពារដោយរដ្ឋធម្មនុញ្ញ ។

-ទឡ្ហីករណ៍

១.ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់ និងការរំលោភអំណាច។ធាតុផ្សំនៃបទល្មើសតាមមាត្រា ៤០ គឺជាតុចេតនា/អត្តនោម័ត "ការដឹង" ។

-តុលាការត្រូវមានភស្តុតាងផ្ទាល់(ការសារភាពថាបានដឹង)តែរឿងនេះពុំមានភស្តុតាងថាលោកស្រី Yoshe [redacted] បានដឹងថាក្នុងកាបូបមានគ្រឿងញៀនណាទេ។

បើមិនមានភស្តុតាងថាបានដឹងនោះហើយបែរប្រើភស្តុតាងប្រយោលគឺគ្រោះថ្នាក់ខ្លាំងណាស់ ភស្តុតាងប្រយោល គឺមានតែការសម្រាំងយកតែភស្តុតាង ដាក់បន្ទុក។

តុលាការមិនមានភស្តុតាងផ្ទាល់ ដែលបញ្ជាក់ថា លោកស្រី Yoshe [redacted] បានដឹងថាក្នុងកាបូបមានគ្រឿងញៀនឡើយ ។ ការផ្អែកលើភស្តុតាងប្រយោលមួយចំនួន ដែលសម្រាំងយកតែភស្តុតាងដាក់បន្ទុក ទាត់ចោលភស្តុតាងដោះបន្ទុក មានហានិភ័យជាខ្លាំងដល់ការវិនិច្ឆ័យរបស់តុលាការ បង្កើតជាវិមតិសង្ស័យ ដែលថា បើតុលាការពិចារណា ភស្តុតាងដោះបន្ទុកដែរនោះ តើមានការផ្លាស់ប្តូរការវិនិច្ឆ័យនេះដែរឬទេ ? ។

-ការយល់ឃើញរបស់សាលាឧទ្ធរណ៍នៅទំព័រ១៣ (ក្នុងសារណា ជូនតុលាការកំពូលនៅទំព័រ២៣បានលើកជូនហើយ ។

-ការយល់ឃើញរបស់សាលាដំបូងទំព័រ៩ក៏បានលើកតបក្នុងសារណានៅទំព័រ ២២ដែរ

សួរថា តើតុលាការថ្នាក់ក្រោមបានពិចារណាគ្រប់ភស្តុតាងទេ ? ចម្លើយគឺទេ ! មិនពិចារណាភស្តុតាងដោះបន្ទុកសំខាន់ៗទេ។

ចំពោះករណីរបាយការណ៍សំយោគរបស់នគរបាលយុត្តិធម៌និងសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ថា Yoshe [redacted] គឺជនរងគ្រោះទទួលរងគ្រោះពីការបោកប្រាស់របស់ឧក្រិដ្ឋជន។ ករណីនៃកាបូបះគេលាក់បាំងហើយបានដេរភ្ជិតដោយម៉ាស៊ីនទំនើបដែលគេមើលនឹងភ្នែកទទេថាមិនឃើញ បានអ្វី ។

ការទទួលប្រាក់ ១.០០០ ដុល្លារអាមេរិកលុយនេះជាសោហ៊ុយធ្វើដំណើរចាយវាយជាការប៉ះប៉ូវការខាតបង់ការដែល Yoshe [redacted] មិនបានបង្រៀននៅអូស្ត្រាលី នេះមិនមែនជាកម្រៃសម្រាប់ការផ្ញើវត្ថុទេ ហើយក៏មិនមានភស្តុតាងក្នុងសំណុំរឿងណានាំស៊ីសង្វាក់នឹងចម្លើយបែបនេះឡើយ បើការសន្មត់ថា ការទទួលប្រាក់ ១.០០០ ដុល្លារអាមេរិកជាកម្រៃសម្រាប់ផ្ញើវត្ថុ សួរថាតើគ្រឿងញៀន ០២ គីឡូក្រាម តម្លៃប៉ុន្មានលានដុល្លារ?និងលុយ១០០០ដុល្លាមិនសមទេ បើលុយ ១០០០ ដុល្លារជាការប៉ះប៉ូវទើបជាការសមរម្យ។ Yoshe [redacted] មានប្រាក់ឧបត្ថម្ភពេលឈប់បង្រៀននៅសាលារដ្ឋ និងបង្រៀនឯកជនបាន ៣០០ ដុល្លារអាមេរិកក្នុង១សប្តាហ៍ដែរ ។ ភស្តុតាងដោះបន្ទុកដូចជា របាយការណ៍ប៉ូលីសយុត្តិធម៌ និងរបាយការណ៍សំយោគ ជាដើម។ ខ្លួនបានសហការណ៍ជាមួយមេធាវីអូស្ត្រាលីអំពីរឿងក្តី Douglas តែរកព័ត៌មានមិនបានរឿងក្តី Douglas ត្រូវបានតុលាការហាមឃាត់មិនឲ្យមានព័ត៌មានចេញក្រៅ ខ្លួនក៏បានធ្វើពាក្យសុំ

តុលាការអូស្ត្រាលី ដើម្បីបានព័ត៌មានយកមកប្រើប្រាស់ជាមួយតុលាការកម្ពុជានគរបាលអូស្ត្រាលីមានព័ត៌មានថា មានក្រុមបណ្តាញគ្រឿងញៀនបានប្រើវិធីសាស្ត្របោកប្រាស់ជនរងគ្រោះនិងជនដែលងាយរងគ្រោះធ្វើឲ្យមានការទុកចិត្តតាមអិនធើណែត និង តាមវើបសាយក្រុមឧក្រិដ្ឋជនទាំងនេះ ក្លែងខ្លួនជាអ្នករកស៊ី ហើយស្វែងរកឲ្យគេធ្វើតំណាងនៅអូស្ត្រាលីហើយឲ្យជនរងគ្រោះមកប្រទេសកម្ពុជា និងនិយាយជាមួយជនរងគ្រោះឲ្យជាប្រាក់បៀវត្តនិងរកការងារឲ្យធ្វើជាតំណាងនៅអូស្ត្រាលី ពេលត្រឡប់ទៅវិញក៏ផ្ញើកាបូបទៅវិញមានដាក់គ្រឿងញៀនដែលគេមិនងាយមើលដឹង។

ចំពោះរឿង Douglas ការជំនុំជម្រះនៅតុលាការ អូស្ត្រាលី រកឃើញថា ពួកគេគឺគ្មានកំហុសនិងមិនដឹងថា កាបូបដែលប្រគល់ឱ្យពួកគេមានគ្រឿងញៀន ដោយសារពួកគេជាជនរងគ្រោះដោយការបោកប្រាស់របស់ក្រុមឧក្រិដ្ឋជន ។ ការបោកប្រាស់ គឺមានវិធីសាស្ត្រដូចគ្នានឹងករណីរបស់លោកស្រី Yoshe [redacted] ដែរ ។ រឿង Douglas នៅអូស្ត្រាលីគេប្រើវិធីសាស្ត្រស្នេហាហើយផ្ញើគ្រឿងញៀន ពេលជនរងគ្រោះវិលទៅអូស្ត្រាលីវិញ មនុស្សធម្មតាមើលមិនឃើញមានគ្រឿងញៀនទេ។

សាលាឧទ្ធរណ៍ និងសាលាដំបូងរាជធានីភ្នំពេញ មិនបានយកកស្តុតាងដោះបន្ទុកមកពិនិត្យ ជារឿងរំលោភអំណាចមួយ ។មាត្រា៣២១នៃក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចឲ្យតុលាការជាន់ក្រោម ពិចារណាលើកស្តុតាងដោះបន្ទុក ។ ការដែលតុលាការបានព្យាយាមយកកស្តុតាងប្រយោលមកប្រើប្រាស់គឺមិនបានពិចារណាលើមាត្រា៤០គឺជាការអនុវត្តខុសច្បាប់លើធាតុផ្សំបទល្មើស ការដែលយកតែកស្តុតាងដាក់បន្ទុកមកប្រើគឺជាការអនុវត្តខុសច្បាប់ ហើយសំអាងហេតុដែលមិនយកកស្តុតាងដោះបន្ទុកមកប្រើនាំឲ្យការអនុវត្តខុសច្បាប់ដែរ។

ជារួមក្នុងរឿង Yoshe [redacted] នេះ គេកសាងជំនឿទុកចិត្តពីសំណាក់ជនរងគ្រោះតាមរយៈទំនាក់ទំនងស្នេហា ប្តូរមកជាទំនាក់ទំនងដោយផ្ទាល់តាមរយៈ ទូរស័ព្ទ ឬជា អ៊ីម៉ែលប្រើល្បិចកលឱ្យជនរងគ្រោះជឿថាជនបោកប្រាស់នេះគឺជាអ្នកធ្វើការឬរកស៊ីខាងអេឡិចត្រូនិច និង ឬវត្ថុសិល្បៈ ប្រើល្បិចកលឱ្យជនរងគ្រោះជឿរថា ជនបោកប្រាស់នេះ មានបំណងបើកហាងលក់ វត្ថុសិល្បៈនៅអូស្ត្រាលី បញ្ឆោតឱ្យផ្ញើទំនិញអេឡិចត្រូនិច ដែលជាគំរូពីអូស្ត្រាលីមកកម្ពុជា បញ្ឆោតឱ្យធ្វើដំណើរពីអូស្ត្រាលី មកកម្ពុជា ដើម្បីជួបមុខគ្នាផ្ទាល់បញ្ឆោតឱ្យជនរងគ្រោះមានទំនុកចិត្ត ពេលត្រឡប់ទៅអូស្ត្រាលីវិញ ពឹងពាក់ឱ្យជនរងគ្រោះយកកាបូបដែលពួកគេប្រាប់ថាមានដាក់ទំនិញជាវត្ថុសិល្បៈវត្ថុអនុស្សាវរីយ៍ ទៅប្រគល់ដល់អតិថិជន ឬដៃគូរ

ពាណិជ្ជកម្មនៅអូស្ត្រាលី ប៉ុន្តែការពិតមានលាក់កំបាំងគ្រឿងញៀន ដែលមិនអាចមើលឃើញនឹងភ្នែកទទេ ទោះបីជាជនរងគ្រោះបានបែកមើលក្នុងកាបូប នោះក៏ដោយ។ ការមិនពិចារណាឱ្យបានល្អិតល្អន់ទៅលើធាតុផ្សំនៃបទល្មើស ពោលធាតុចេតនា គឺការបំពានច្បាប់ ឬការអនុវត្តដោយខុសច្បាប់ ។

២.ការបំភ្លៃអង្គហេតុ

សំអាងហេតុដែលមិនសម្រិតសម្រាំងតែលើកស្តុតាងប្រយោលដាក់បន្ទុកដើម្បី ធ្វើជាមូលដ្ឋានកំណត់អង្គហេតុ ធ្វើឱ្យមានរូបភាពតែម្ខាង (គេមិនអាចរកការពិតឃើញតាមរបៀបនេះទេ) ហាក់បីដូចជាមិនមានអង្គហេតុអ្វីផ្សេងទៀតសម្រាប់ដោះបន្ទុកៗនេះបង្កើតជាការបំភ្លៃអង្គហេតុ

៣.ការគ្មានសំអាងហេតុ

នៅក្នុងឧទាហរណ៍ទាំង៤តុលាការមិនវាយតម្លៃ (ពិចារណា) កស្តុតាងដោះបន្ទុកហើយតុលាការមិនផ្តល់សំអាងថាហេតុអ្វី បានជាតុលាការមិនយកកស្តុតាងដោះបន្ទុកទាំងនេះមកវាយតម្លៃ (ពិចារណា)។ សាលក្រមសាលាដំបូងទំព័រ១០ "មេធាវីការពារសិទ្ធិជនជាប់ចោទថាកូនក្តីគ្រាន់ តែជាជនរងគ្រោះត្រូវគេអូសទាញ ពុំមានពាក់ព័ន្ធគ្រឿងញៀនទេ សុំឱ្យកូនក្តីរួចពីបទចោទ គប្បីតុលាការមិនពិចារណា" ។ តុលាការមិនផ្តល់សំអាងហេតុថា ហេតុអ្វីការសន្និដ្ឋានការពារដែលផ្អែកលើកស្តុតាងដោះបន្ទុកបែបនេះមិនត្រូវតុលាការយកទៅពិចារណា ។

III .សេចក្តីសន្និដ្ឋាន និងសំណើរសុំ

ក្រុមប្រឹក្សាជាទីគោរពតាមការសង្ខេបមូលដ្ឋាន និងហេតុផលខាងលើជឿជាក់ថា មានការបំពានសិទ្ធិលើ Yoshe [redacted] សិទ្ធិទទួលបានការសន្មត់ទុកជាមុនថាគ្មានទោស ដែលកំណត់ថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។ ហេតុដូច្នេះហើយ បានជាឈានមកដល់ដំណាក់កាលនេះ មានសវនាការថ្ងៃនេះ ដើម្បីប៉ះប៉ូវនូវភាពអយុត្តិធម៌ ដែលមានលើ Yoshe [redacted]

ជឿជាក់ថា Yoshe [redacted] ជាជនរងគ្រោះពីការបោកប្រាស់ របស់ជនខិលខូច តុលាការកំពូលនឹងផ្តល់យុត្តិធម៌ឲ្យ [redacted] Taylor រួចផុតពីការចោទប្រកាន់ហើយបានរួចខ្លួនទៅជួបមុខកូននិងក្រុមគ្រួសារនិងមានសេរីភាពឡើងវិញ។

សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងសុំបង្វិលសំណុំរឿងនេះឱ្យសាលាឧទ្ធរណ៍ជំនុំជម្រះឡើងវិញ សុំដោះលែង [redacted] Taylor ឱ្យបាននៅក្រៅឃុំបណ្តោះអាសន្នឬសុំឲ្យ

ដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ខណៈពេលរង់ចាំការជំនុំជម្រះឡើងវិញរបស់សាលាឧទ្ធរណ៍ ។

-តំណាងមហាអយ្យការបានសន្និដ្ឋានបន្ថែមថា តាមចម្លើយដែលបានឆ្លើយមានការសង្ស័យជាច្រើនលើឈ្មោះ [redacted] Taylor ព្រោះគាត់ជាអ្នកកណ្តាល ហើយក៏ជាជនរងគ្រោះ ដោយមានបណ្តាញរកស៊ីគ្រឿងញៀន ផ្តើមចេញពីមិត្តភ័ក្តិ និងជាអ្នករកការងារឱ្យធ្វើ ។ ឯឈ្មោះ Nwoko [redacted] ជាអ្នកមានតួនាទីសំខាន់ធ្វើឱ្យបណ្តាយគ្រឿងញៀនដើរទៅមុខ ។ សូមតុលាការសម្រេចតាមច្បាប់ចុះ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានសុំរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៥៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ឈ្មោះ អ៊ិនវូកូ ព្រីហ្វីស ឈីនីមេ ( Nwoko [redacted]) និងបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ ថេល័រ យូសេ អាន (Yoshe [redacted])ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.យល់ឃើញថា នៅក្នុងសំណុំរឿងនេះ មានជនជាប់ចោទចំនួន បួននាក់ ប៉ុន្តែមានជនជាប់ចោទចំនួនពីរនាក់បានប្តឹងសាទុក្ខ ហេតុនេះ តុលាការកំពូលពិចារណាតែក្នុងក្របខណ្ឌនៃបណ្តឹងសាទុក្ខចំពោះជនជាប់ចោទចំនួនពីរនាក់ដែលបានប្តឹងសាទុក្ខប៉ុណ្ណោះ ។

៣.យល់ឃើញថា ជនជាប់ចោទឈ្មោះ អ៊ិនវូកូ ព្រីហ្វីស ឈីនីមេ (Nwoko [redacted] Chineme ) (តទៅនេះហៅថា អ៊ិនវូកូ) បានលើកឡើងថា ការឆែកឆេរលំនៅរបស់ខ្លួនបានធ្វើឡើងដោយមិនមានការអនុញ្ញាត ពីព្រះរាជអាជ្ញា ខ្លួនត្រូវបានឃាត់ខ្លួនដោយមិនមានដីកាពីតុលាការ វត្ថុតាងត្រូវបានចាប់យកដោយមិនមានវត្តមានរបស់ខ្លួន ការឃាត់ខ្លួនបានធ្វើឡើងនៅម៉ោង៨ និង២០យប់ រហូតដល់១៦៨ម៉ោង ដោយគ្មានកស្តុតាងខ្លួនត្រូវបានបង្ខំឱ្យចុះហត្ថលេខា

ដោយមិនមានវត្តមានរបស់មេធាវី និងអ្នកបកប្រែភាសានៅអង្គភាពនគរបាល និងមិនមានកស្តុតាងដាក់បន្ទុកលើខ្លួនឡើយ ។

ចំពោះការលើកឡើងដូចខាងលើនេះ តុលាការកំពូលពិចារណាឃើញថា ក្រោយពីដីកាដំណោះស្រាយបានចូលជាស្ថាពរ គ្មានមោឃភាពណាមួយ នៃនីតិវិធីមុនអាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយតាមមាត្រា២៥៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ម្យ៉ាងវិញទៀតផ្អែកតាមឯកសារក្នុងសំណុំរឿងបានបង្ហាញឱ្យឃើញថា ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ ធ្វើឡើងក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែងដោយការឆែកឆេរផ្ទះលេខ១៧B ផ្លូវលេខ៥១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រូវបានធ្វើឡើងក្រោមការដឹកនាំរបស់លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយមានវត្តមានរបស់ជនជាប់ចោទផ្ទាល់ (កំណត់ហេតុឆែកឆេរ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣) ហើយកំណត់ហេតុស្តាប់ចម្លើយរបស់ជនជាប់ចោទមានវត្តមានរបស់អ្នកបកប្រែភាសាបរទេស និងនីតិវិធីនៃការឃាត់ខ្លួនក៏បានធ្វើឡើងស្របតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ ។

ចំពោះការលើកឡើងពីកង្វះកស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះអ៊ិនវូកូ តុលាការកំពូលពិនិត្យឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ថេល័រ យូសេ អាន (Yoshe A[redacted] Taylor ) (តទៅនេះហៅថា ថេល័រ) និងចម្លើយរបស់ជនជាប់ចោទឈ្មោះ សាវ៉ារីណូ ហ្សាលីន (Savarino [redacted] ) បង្ហាញឱ្យឃើញថា កាបូបមានផ្ទុកគ្រឿងញៀនដែលជនជាប់ចោទឈ្មោះ ថេល័រ កាន់យកចូលក្នុងព្រលានយន្តហោះ បានយកមកពីផ្ទះរបស់ជនជាប់ចោទឈ្មោះ អ៊ិនវូកូ ហើយក៏ស៊ីសង្វាក់ជាមួយនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ អ៊ិនវូកូ ដែលបាន ទទួលស្គាល់ថា ខ្លួនបានផ្ញើវត្ថុសិល្បៈតាមរយៈឈ្មោះ ថេល័រ មែន ដោយខ្លួនបានឱ្យប្រាក់ទៅ ឈ្មោះ Ojukwu T[redacted] ហៅ អ៊ិនតូ ( NTO ) (តទៅនេះហៅថា អ៊ិនតូ ) ទៅទិញកាបូប និងវត្ថុសិល្បៈ ។ ទោះបីជាជនជាប់ចោទឈ្មោះ អ៊ិនវូកូ បដិសេធថា ខ្លួនមិនបានដឹងពីរឿងគ្រឿងញៀនដោយសារតែឈ្មោះ [redacted] ជាអ្នកទិញកាបូប និងជាអ្នកយកមកទុកនៅក្នុងផ្ទះរបស់ខ្លួន ក៏ដោយ ប៉ុន្តែយោងតាមកស្តុតាងក្នុងសំណុំរឿងដូចជាចម្លើយរបស់ឈ្មោះ សាវ៉ារីណូ ហ្សាលីន ដែលថាឈ្មោះ អ៊ិនវូកូ បានប្រាប់ខ្លួនឱ្យប្រាប់ឈ្មោះ ថេល័រ ថា នាងធ្វើការនៅក្រុមហ៊ុនក្រណាត់ប៉ាក់ និងលក់គ្រឿងចម្លាក់ ក្រុមហ៊ុន KNN ក៏ដូចជាចម្លើយរបស់ឈ្មោះ ថេល័រ ដែលបញ្ជាក់ថា ឈ្មោះ អ៊ិនវូកូ បានប្រាប់ខ្លួនជាមុនថា នឹងផ្ញើវត្ថុសិល្បៈតាមរយៈនាង នៅពេលដែលនាងត្រឡប់ទៅប្រទេសអូស្ត្រាលីវិញ ហើយកាបូបនោះក៏ត្រូវបានឈ្មោះ សាវ៉ារីណូ ហ្សាលីន ដែល

ជាមិត្តស្រីរបស់ អ៊ិនវូក្ង យកចេញពីផ្ទះរបស់ឈ្មោះ អ៊ិនវូក្ង ដែរ ។ កស្តុតាងទាំងនេះមានលក្ខណៈធ្ងន់ល្មមអាចឱ្យតុលាការថ្នាក់ក្រោមកំណត់បានថា ជនជាប់ចោទឈ្មោះ អ៊ិនវូក្ង និងបក្សពួកបានរៀបចំគម្រោងទុកដាក់គ្រឿងញៀននៅក្នុងកាបូប ហើយផ្ញើតាមឈ្មោះ ថេល័រ យកទៅប្រទេសអូស្ត្រាលី នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ ។

៤.យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំអាងហេតុថា ថ្នាំញៀនត្រូវបានដកហូតពីជនជាប់ចោទឈ្មោះ ថេល័រ ដាក់ស្ដែងនៅព្រលានយន្តហោះ ហើយសន្និដ្ឋានថា មានពិរុទ្ធភាពលើជនជាប់ចោទរូបនេះពីបទ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន គឺនៅមិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ព្រោះថា ៖

ក.តាមមាត្រា៤ នៃក្រមព្រហ្មទណ្ឌ ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ដូច្នេះ ដើម្បីកំណត់បាននូវពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ ថេល័រ តុលាការចាំបាច់ត្រូវមានសំអាងហេតុជាក់លាក់ពីធាតុផ្សំអត្តនោម័ត ដែលជាចេតនាទុច្ចរិតរបស់ជនជាប់ចោទពោលគឺនៅក្នុងរឿងក្ដីនេះ សំដៅទៅលើចេតនាដឹកជញ្ជូនសារធាតុ ដែលជនជាប់ចោទបានដឹងថាជាសារធាតុញៀន ដែលច្បាប់ហាមឃាត់ ។

ខ.ចំពោះករណីនេះតុលាការកំពូលពិនិត្យឃើញថាសាលាឧទ្ធរណ៍នៅមិនទាន់ បានលើកយកមកពិចារណានូវរបាយការណ៍ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣ របស់ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន នៃនាយកដ្ឋានប្រឆាំងគេរវកម្ម នៃក្រសួងមហាផ្ទៃ ដែល គូសបញ្ជាក់ថា "ឈ្មោះ Taylor [redacted] អាចជាអ្នកចាញ់កលល្បិចដ៏ប៉ិនប្រសប់របស់ឈ្មោះ Precious..." និងចម្លើយរបស់លោក [redacted] ជាមន្ត្រីនគរបាលដែលថា គ្រឿងញៀនដាក់ក្នុងជញ្ជាំងកាបូបមើលនឹងភ្នែកពុំអាចដឹងទេ ។ ម្យ៉ាងវិញទៀត ផ្អែកតាមរបាយការណ៍នេះ ក៏បានបង្ហាញដែរថា ការស៊ើបអង្កេតដែលឈានទៅដល់ការចាប់ខ្លួនជនជាប់ចោទនៅក្នុងរឿងក្ដីនេះ គឺដោយសារតែការចាប់ខ្លួនជនជាតិអូស្ត្រាលីពីររូបឈ្មោះ Cathryn [redacted]ll និងឈ្មោះ David [redacted] ដែលត្រូវបានឈ្មោះ អ៊ិនវូក្ង និងឈ្មោះ សាវ៉ារីណូ ហ្វាលីន ផ្ញើវ៉ាលី និងកាបូបស្ពាយចំនួន០៤ ដោយមានលាក់គ្រឿងញៀន ហើយត្រូវចាប់ខ្លួននៅប្រទេសអូស្ត្រាលី ។ នៅចំពោះមុខតុលាការកំពូល មេធាវីការពារជនជាប់ចោទឈ្មោះ ថេល័រ បានផ្ដល់ឯកសារពាក់ព័ន្ធនឹងការសម្រេចឱ្យរួចខ្លួនលើឈ្មោះ David [redacted] និងប្រតិចារិកក្នុងរឿងក្ដីរបស់លោក David [redacted] ដែលអាចជាមូលដ្ឋានសម្រាប់ឱ្យសាលាឧទ្ធរណ៍ធ្វើការពិចារណាជាបន្ថែមទៀត ពាក់ព័ន្ធនឹងអត្ថិភាព ឬនត្ថិភាពនៃធាតុផ្សំអត្តនោម័ត ចំពោះករណីជនជាប់ចោទឈ្មោះ ថេល័រ ។

៥.យល់ឃើញថា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ អ៊ិនវ៉ូកូ មិនមានមូលហេតុនៃបណ្ដឹងសាទុក្ខ ស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៦.យល់ឃើញថា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ ថេល័រ មានមូលហេតុត្រឹមត្រូវតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់ចំណុចការអនុវត្តខុសច្បាប់ និងការគ្មានសំអាងហេតុអំពីធាតុផ្សំអត្តនោម័ត ។

៧.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១១៨ ក្រVបស ចុះថ្ងៃទី០៦ខែធ្នូឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមច្បាប់ខ្លះ ខុស ច្បាប់ខ្លះ ។

៨.យល់ឃើញថា នាពេលសវនាការតុលាការកំពូល ក៏ដូចជាក្នុងសារណាការពារ នៃបណ្ដឹងសាទុក្ខ លោកមេធាវីការពារឱ្យជនជាប់ចោទបានស្នើសុំឱ្យតុលាការកំពូលដោះលែងជនជាប់ចោទឈ្មោះ ថេល័រ ជាបណ្ដោះអាសន្ន ក្នុងករណីដែលតុលាការកំពូលសម្រេចបញ្ជូនសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ឱ្យពិចារណាសាជាថ្មី ។ ចំពោះសំណើសុំនេះតុលាការកំពូលយល់ឃើញថា រឿងក្ដីនេះជាបទឧក្រិដ្ឋពាក់ព័ន្ធនឹងបទល្មើស ដឹកជញ្ជូនសារធាតុញៀនធ្ងន់ដែនដែលការឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្នជាវិធានការចាំបាច់ ដើម្បីធានារក្សាទុកជនជាប់ចោទទុកជូនតុលាការកម្ពុជាចាត់ការតាមនីតិវិធីស្របតាមមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ហេតុដូច្នេះ**

**សម្រេច**

១.បដិសេធបណ្ដឹងសាទុក្ខលេខ ៤៥៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ឈ្មោះ អ៊ិនវ៉ូកូ ព្រីហ្វ៊ីស ឈីនីមេ ( Nwoko [redacted] ) ។

២.ទទួលបណ្ដឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ ថេល័រ យូសេ អាន (Yoshe [redacted]) ។

៣.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១១៨ ក្រVបស ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចដែលសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥០កប២ "ឆ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ អ៊ិនវ៉ូកូ ព្រីហ្វ៊ីស ឈីនីមេ ( Nwoko [redacted] ) ប៉ុន្តែបដិសេធចំណុចដែលពាក់ព័ន្ធនឹងការផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ ថេល័រ យូសេ អាន (Yoshe [redacted]) ។

៤.បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៧១ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ ត្រង់ចំណុចដែលត្រូវបានបដិសេធដូចខាងលើ ។

៩.មិនព្រមដោះលែងជនជាប់ចោទឈ្មោះ ថេល័រ យូសេ អាន (Yoshe [redacted] )ឱ្យ

នៅក្រៅឃុំ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ ។

-លោកស្រី [redacted] ជាប្រធាន

-លោក [redacted] ជាចៅក្រម

-លោក [redacted] ជាចៅក្រម

-លោក [redacted] ជាចៅក្រម

-លោកស្រី [redacted] ជាចៅក្រម

-លោក [redacted] ជាក្រឡាបញ្ជី

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ៨កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃសុក្រ ៨កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨

**សភាព្រហ្មទណ្ឌ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]